ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម

លេខ ០៤១/២៥ ន.គ.ស/អ.ជ.ណ.

ថ្ងៃ សុក្រ ៧ កើត ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ គ.ស.២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ( នីតិបុគ្គល និងរូបវន្តបុគ្គល )

និយ័តករគណនេយ្យនិងសវនកម្ម ( **ន.គ.ស.** ) សូមជម្រាបជូនដំណឹងដល់ម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសាធារណជនជ្រាបថា៖ **ន.គ.ស.** បានសម្រេចដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម តាមសំណើសុំរបស់ម្ចាស់អាជ្ញាបណ្ណដូចខាងក្រោម៖

- ក្រុមហ៊ុន ដូហូ ឆាធើរ អឹខោនថិន (ខេមបូឌា) ឯ.ក ដែលមានលេខអាជ្ញាបណ្ណ ០១០១/២៥ ន.គ.ស.អ.ជ.ស.( នីតិបុគ្គល )
- លោក MAK LEUNG HEI ដែលមានអាជ្ញាបណ្ណលេខ ០៦០/២៣ ន.គ.ស.អ.ជ.ស (រូបវន្តបុគ្គល)។

ដូចនេះ **ន.គ.ស**. សូមជម្រាបដល់ម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសាធារណជន ដែលមានបំណងប្រើប្រាស់សេវាគណនេយ្យនិងសវនកម្ម សូមធ្វើការផ្អាក ឬកុំប្រើប្រាស់សេវាគណនេយ្យនិង សវនកម្ម ដែលផ្តល់ដោយក្រុមហ៊ុន ដូហូ ឆាធើរ អឹខោនថិន (ខេមបូឌា) ចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥ ដោយហេតុថា ក្រុមហ៊ុនបានបាត់បង់នីតិសម្បទាក្នុងការផ្តល់សេវាគណនេយ្យនិងសវនកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

អាស្រ័យហេតុនេះ សូម ម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសាធារណជនជ្រាបជាព័ត៌មាន។

**និយ័តករគណនេយ្យនិងសវនកម្ម**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
ទូរស័ព្ទ ០៩៥ - ២៣ ៨៨២ ១១១
Phone: 023 882 111
អ៊ីមែល : info@acar.gov.kh